# ក

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


០៥-៣-២០០១ -ព្រះរាជក្រឹត្យ ជស/រកត/០៣០១/០២ តែងតាំងលោក **ស៊ន សុខណា** ជាឧកញ៉ា ៥៧៤

០៥-៣-២០០១ -ព្រះរាជក្រឹត្យ ជស/រកត/០៣០១/០៣ បញ្ចប់ភារកិច្ច ឯកឧត្តម **ជុំ ភារណាល់** ពីទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី ៥៧៥

០៨-៣-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៣០១/០៤៩ ស្តីពីការបង្កើតសញ្ញាសក្តិ ឯកសណ្ឋានសំរាប់សំគាល់មន្ត្រីរាជការក្របខ័ណ្ឌ មន្ត្រីរដ្ឋបាលជាន់ខ្ពស់និងក្របខ័ណ្ឌមន្ត្រីក្រមការ ដែលស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ ៥៧៦


## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ


០២-៣-២០០១ -អនុក្រឹត្យលេខ ២៦ អនក្រ.បក ស្តីពីការបង្កើត និងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ ៦០២

០៥-៣-២០០១ -អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការលុបនាទីឡូត+ នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត+នេសាទ ខេត្តព្រៃវែង ទុកសំរាប់ប្រជាពលរដ្ឋ ធ្វើនេសាទជាលក្ខណៈ គ្រួសារ ៦០៣

០២-៣-២០០១ -អនុក្រឹត្យលេខ ៩២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦០៦

០៦-៣-២០០១ -អនុក្រឹត្យលេខ ៩៣ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦០៧

០៦-៣-២០០១ -អនុក្រឹត្យលេខ ៩៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦០៩

០៦-៣-២០០១ -អនុក្រឹត្យលេខ ៩៥ អនក្រ.តត ស្តីពីការជូនមេដាយមុនី សារាភ័ណ្ឌ ៦១០

០៦-៣-២០០១ -អនុក្រឹត្យលេខ ៩៦ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦១១

០៧-៣-២០០១ -អនុក្រឹត្យលេខ ៩៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦១៣

០៧-៣-២០០១ -អនុក្រឹត្យលេខ ៩៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦១៤

០៧-៣-២០០១ -អនុក្រឹត្យលេខ ៩៩ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦១៥

០៧-៣-២០០១ -អនុក្រឹត្យលេខ ១០០ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនា
ជាតិ ៦១៦

០៧-៣-២០០១ -អនុក្រឹត្យលេខ ១០១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦១៧

០៧-៣-២០០១ -អនុក្រឹត្យលេខ ១០២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦១៨

## ២.សេចក្តីសំរេច

០៦-០៣-២០០១ -សេចក្តីសំរេចលេខ ១១ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះ
នៃកិច្ចសហប្រតិបត្តិការកម្ពុជាឥណ្ឌូណេស៊ី ៦១៩

០៧-០៣-២០០១ -សេចក្តីសំរេចលេខ ១២ សសរ ស្តីពីការបង្កើតគណៈកម្មាធិការ
ជាតិផ្សងថ្មកម្ពុជា ៦២២

០៧-០៣-២០០១ -សេចក្តីសំរេចលេខ ១៣ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះ
អន្តរក្រសួង ដើម្បីស្រាវជ្រាវត្រួតពិនិត្យប្រមូលពត៌មាន ជុំវិញបញ្ហា
ផ្សារបឹងឈូក និងបញ្ហាដេញថ្លៃភាស៊ីស្តង់ត្រីស្រស់នៅខេត្តបាត់ដំបង ៦២៥

# គ

## III- ការងារបណ្ដាក្រសួង

### ទីស្ដីការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

### ប្រកាស


| | | |
|---|---|---|
| ០៦-០៣-២០០១ | -ប្រកាសលេខ ១៦៥ ឧរថក។ប្រក អនុញ្ញាតអោយក្រុមហ៊ុនលៀន អ៊ីតិចថាយ ( ខេមបូឌា ) ខូអិលធីឌី តំណាងដោយលោក LIN CHAO HSIN សញ្ជាតិចិន ( តៃវ៉ាន់ ) បង្កើតរោងចក្រតម្បាញ និងកាត់សំលៀកបំពាក់ | ៦២៦ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

**ព្រះរាជក្រឹត្យ ជស/រកត/០៣០១/០២**

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

**តែងតាំង**

**លោក ស៊ិន សុខណា**

**ជា**

**ឧកញ៉ា**

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែ មិនា ឆ្នាំ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

❋

# ព្រះរាជក្រឹត្យ ជស/រកត/០៣០១/០៣

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតនៈ

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានបញ្ឈប់ភារកិច្ចឯកឧត្តម **ជុំ ភារណារស់** ពីទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា អោយទៅបំរើការងារក្នុងក្របខ័ណ្ឌដើមវិញ ។

**មាត្រា ២ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

**ជា ស៊ីម**

# ព្រះរាជក្រឹត្យ នស/រកត/០៣០១/០៤៩
# ស្តីពីការសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
# នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ
# របស់ក្រសួងមហាផ្ទៃ

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតណ៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០០/០៧៥ ចុះថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីក្រមការ នៃក្រសួងមហាផ្ទៃ

- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់នាយករដ្ឋមន្ត្រី ដែលបានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០១

## ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត សញ្ញាសក្តិ ឯកសណ្ឋានសំរាប់សំគាល់មន្ត្រីរាជការក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ ដែលស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ ។

**មាត្រា ២.-**

សញ្ញាសក្តិ និងឯកសណ្ឋាននេះ សំរាប់ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

## ជំពូកទី ២

## សញ្ញាសក្តិ

**មាត្រា ៣.-**

សញ្ញាសក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ របស់ក្រសួងមហាផ្ទៃ ត្រូវបានកំណត់ដូចតទៅ :

**ក.ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ :**

**១.អំពីមួក :**

មួកកាសស្តេតពណ៌ស និងមានក្បាំងខាងមុខពណ៌ខៀវចាស់ . នៅផ្នែកខាងលើមុខមួក មានប៉ាក់ឱនរូបព្រះរាជសង្ហារពណ៌មាស . ជាយក្បាំងខាងលើ មានផ្ទៃពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ផ្កាឈូកបីទងពណ៌មាសនៅចំកណ្តាល និងអមដោយក្បាច់សន្លឹកភ្នីទេសនៅសងខាង . ចំកណ្តាលក្បាំងមានខ្សែវ័ណ្ណក្រឡាក្លែបពណ៌មាសនៅពីលើ ហើយនៅចុងទាំងសងខាង នៃខ្សែក្រឡាក្លែបនេះមានលំអដោយឡេវរូបព្រះរាជសង្ហារពណ៌មាសមួយ . ជាយក្បាំងខាងមុខ មានរចនាតុបតែងដោយក្បាច់ផ្កាឈូកបីស្រទាប់ពណ៌មាសនៅចំកណ្តាល បន្ទាប់មកមានក្បាច់កួរស្រូវ និងក្បាច់សន្លឹកភ្នីទេសនៅអមសងខាងផង ។ ជាយក្បាំងខាងមុខមួកនេះ មានក្បាច់រចនាពេញ ចំពោះឋានន្តរសក្តិឧត្តមមន្ត្រី

ពីរភាគបី ចំពោះឋានន្តរសក្តិវរៈមន្ត្រី និងមួយកន្លះភាគបី ចំពោះឋានន្តរសក្តិអនុមន្ត្រី . នៅចុងជាយក្បាំងខាងក្រោមបង្អស់ មានខ្សែវ័ណ្ឌពណ៌មាស រាងដងធ្នូសំប៉ែតមួយផង ។

រូបគំនូរម្កុដ និងសញ្ញាសក្តិម្កុដ សំរាប់មន្ត្រី :

-ឋានន្តរសក្តិឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី១

-ឋានន្តរសក្តិវរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ២

-និងឋានន្តរសក្តិអនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៣ នៃព្រះរាជក្រឹត្យនេះ .

**២-អំពីសក្តិស្មា :**

សក្តិស្មា មានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់គូរស្រូវពណ៌មាស និង ក្បាច់សន្លឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយនៅពីលើក្បាច់ទាំងពីរនេះ មានរូបសញ្ញាក្រសួងមហាផ្ទៃពណ៌មាស និងនៅពីខាងលើរូបសញ្ញាក្រសួងមហាផ្ទៃ មានឡេវរូបព្រះរាជសង្ហារពណ៌មាសមួយ . បន្ទាប់មក មានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញក្នុងឋាន . ផ្ទៃខាងក្រៅ នៃក្បាច់ធ្មេញក្របីនេះ មានខ្សែពួរវេញព័ទ្ធជុំវិញពណ៌មាសបី សំរាប់សំគាល់ឋានន្តរសក្តិឧត្តមមន្ត្រី ពីរសំរាប់សំគាល់ឋានន្តរសក្តិវរៈមន្ត្រី និងមួយសំរាប់សំគាល់ឋានន្តរសក្តិអនុមន្ត្រី ។

ខ្នាតសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោម :

-បាតក្រោម ប្រវែង ៦ សង្ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ៤,៤០ សង្ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្តោយពីលើដល់បាតក្រោម ប្រវែង ១៣ សង្ទីម៉ែត្រ

**៣-អំពីសក្តិចុងកអាវ :**

សក្តិចុងកអាវ មានផ្ទៃកម្ពីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់គូរស្រូវពណ៌មាស និង ក្បាច់សន្លឹកភ្ញីទេសពណ៌មាសដាក់ខ្វែងគ្នា ហើយមានរូបសញ្ញាក្រសួងមហាផ្ទៃពណ៌មាសនៅពីខាងមុខ . បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសព័ទ្ធជុំវិញ និងមានខ្សែពួរវេញពណ៌មាស នៅផ្នែកខាងលើភ្ជាប់ជាមួយចំហៀងខាងមុខបី សំរាប់សំគាល់ឋានន្តរសក្តិឧត្តមមន្ត្រីពីរ សំរាប់សំគាល់ឋានន្តរសក្តិ វរៈមន្ត្រី និងមួយសំរាប់សំគាល់ឋានន្តរសក្តិអនុមន្ត្រីទី ។

ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោម :

-មានរាងជាប្រលេឡូក្រាម

-បណ្តោយ ប្រវែង ១១ សង្ទីម៉ែត្រ

-ទទឹង ប្រវែង ៤ សង្ទីម៉ែត្រ

**៤-អំពីសក្តិចុងដៃអាវទាំងសងខាង :**

សក្តិចុងដៃអាវ មានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស និងមានក្បាច់កួរស្រូវពណ៌មាសមួយនៅខាងចុងហើយក្បាច់ កួរស្រូវមួយទៀតខ្វែងនឹងគល់ក្បាច់ភ្ញីទេស . បន្ទាប់មកមានបន្ទះក្បាច់ធ្មេញក្របីពណ៌មាសនៅជាយ ផ្នែកខាងលើ និងផ្នែកសងខាង . ផ្ទៃខាងក្រៅនៃក្បាច់ធ្មេញក្របីនេះ មានខ្សែពួរវេញពណ៌មាសនៅ ផ្នែកខាងលើ និងផ្នែកចំហៀងទាំងសងខាងបីសំរាប់សំគាល់ឋានន្តរសក្តិឧត្តមមន្ត្រី ពីរសំរាប់សំគាល់ ឋានន្តរសក្តិវរៈមន្ត្រី និងមួយសំរាប់សំគាល់ឋានន្តរសក្ត អនុមន្ត្រី . នៅបាតក្រោមបង្អស់ នៃសញ្ញាសក្តិ ចុងដៃអាវ មានខ្សែពួរវេញពណ៌មាសមួយ ។

ខ្នាត នៃសក្តិចុងដៃអាវទាំងសងខាង ត្រូវបានកំណត់ដូចក្រោម :

-មានរាងបួនជ្រុងទ្រវែង

-បណ្តោយ ប្រវែង ៣២ សង្ទីម៉ែត្រ

-ទទឹង ប្រវែង ១១ សង្ទីម៉ែត្រ

រូបគំនូរសញ្ញាសក្តិស្មា សក្តិចុងកអាវ សក្តិចុងដៃអាវទាំងសងខាង សំរាប់មន្ត្រី :

-ឋានន្តរសក្តិ ឧត្តមមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី ៤

-ឋានន្តរសក្តិ វរៈមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៥

-និងឋានន្តរសក្តិ អនុមន្ត្រី មានដូចក្នុងឧបសម្ព័ន្ធទី៦ នៃព្រះរាជក្រឹត្យនេះ .

ដោយឡែកសក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវទាំងសងខាង សំរាប់នារី មានទំហំតូចជាង បុរស ១ សង្ទីម៉ែត្រកន្លះ ។

**៥-អំពីសក្តិខ្ទាស់លើដើមទ្រូងខាងឆ្វេង សំរាប់នារី**

សក្តិខ្ទាស់លើដើមទ្រូងខាងឆ្វេងសំរាប់នារី មានផ្ទៃកម្ទីពណ៌ខៀវចាស់ រាងសាជី ដែលបាតក្រោមមានរាងពងក្រពើ និងកំពូលរាងជ្រលម កំពស់ ៥.៥០ សង្ទីម៉ែត្រ ទទឹង ៤.៥០ សង្ទីម៉ែត្រ .

ផ្នែកខាងក្នុងមានរូបសញ្ញាក្រសួងមហាផ្ទៃពណ៌មាស ទ្រដោយក្បាច់កូរស្រូវពណ៌មាននៅខាងឆ្វេង ដាក់ខ្វែងគ្នានឹងក្បាច់សន្លឹកភ្ញីទេសពណ៌មាសនៅខាងស្តាំ . បន្ទាប់មកមានក្បាច់ផ្តេញក្របីពណ៌មាសមួយព័ទ្ធអមផង . ផ្នែកខាងក្រៅ មានខ្សែពួរវេញព័ទ្ធអមពណ៌មាសបី សំរាប់សំគាល់ឋានន្តរសក្តិឧត្តមមន្ត្រី ពីរសំរាប់សំគាល់ឋានន្តរសក្តិវរៈមន្ត្រី និងមួយសំរាប់សំគាល់ឋានន្តរសក្តិអនុមន្ត្រី ។

រូបគំនូរសក្តិខ្លាស់លើដើមទ្រូងខាងឆ្វេង សំរាប់មន្ត្រីជានាទីទាំងបីឋានន្តរសក្តិ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ មាននៅក្នុងឧបសម្ព័ន្ធទី៧ នៃព្រះរាជក្រឹត្យនេះ ។

**ខ~ក្របខ័ណ្ឌមន្ត្រីក្រមការ :**

សញ្ញាសក្តិសំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ មានសណ្ឋាន និងមានការកំណត់បែងចែកទៅតាមប្រភេទឋានន្តរសក្តិដូចសញ្ញាសក្តិមន្ត្រីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ដែរ

ប៉ុន្តែខុសគ្នាត្រង់សញ្ញាសក្តិសំរាប់ ក្របខ័ណ្ឌមន្ត្រីក្រមការ មានពណ៌ប្រាក់ ។

រូបគំនូរមួក និងសញ្ញាសក្តិមួក សំរាប់មន្ត្រី :

-ឋានន្តរសក្តិនាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី៨

-ឋានន្តរសក្តិក្រមការដើមខ្សែ មានដូចក្នុងឧបសម្ព័ន្ធទី៩

-និងឋានន្តរសក្តិក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី១០ នៃព្រះរាជក្រឹត្យនេះ ។

រីឯរូបសញ្ញាសក្តិស្មា សក្តិចុងកអាវ សក្តិចុងដៃអាវ ទាំងសងខាង សំរាប់មន្ត្រី :

-ឋានន្តរសក្តិ នាយក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី១១

-ឋានន្តរសក្តិក្រមការដើមខ្សែ នៅក្នុងឧបសម្ព័ន្ធទី១២

-និងសំរាប់ឋានន្តរសក្តិក្រមការ មានដូចនៅក្នុងឧបសម្ព័ន្ធទី១៣ នៃព្រះរាជក្រឹត្យនេះ ។

ចំពោះសក្តិខ្លាស់លើដើមទ្រូងខាងឆ្វេង សំរាប់មន្ត្រីជានាទីទាំងបីឋានន្តរសក្តិ នៃក្របខ័ណ្ឌមន្ត្រីក្រមការ មានដូចក្នុងឧបសម្ព័ន្ធទី១៤ នៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ប្រភេទឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ៤ ._**

ប្រភេទឯកសណ្ឋាន សំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃត្រូវបានកំណត់ដូចខាងក្រោម :

**ក._ឯកសណ្ឋានផ្លូវការ :**

**១._ចំពោះបុរស :** អាវវ៉ារីពណ៌ស និង ខោជើងវែងពណ៌ស .

-អាវវ៉ារីមានផែកខ្នង កបើក ដៃវែង មានប៉ូលស្មាទាំងសងខាង មានហោប៉ៅបួនដេរប៉ះ "ហោប៉ៅលើពីរដេរបត់ផ្គត់កណ្តាល មានគំរបរាងស្លឹកពោធិ ហោប៉ៅខាងក្រោមពីរ មានគំរបរាងកាតុកោណកែង", ហោប៉ៅនីមួយ១ មានឡេវបញ្ចោតមួយ ដែលមានរូបព្រះរាជសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរសក្តិ . អាវនេះមានឡេវ ០៥ គ្រាប់ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមឋានន្តរសក្តិ . ចុងដៃអាវកាត់រាងបំពង់ មានឡេវបញ្ចេត ចំនួនបី រូបព្រះរាជសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរសក្តិ ។

-ខោជើងវែងផ្ទេរបង្កប់ ចង្កេះត មានហោប៉ៅបួន " ខាងក្រោយពីរដេរបង្កប់ មានគំរបរាងស្លឹកពោធិ និងនៅចំហៀងពីរ ដេរបង្កប់តាមផ្ទេរ ។

-មួកកាសស្កេត សក្តិស្មា សក្តិចុងកអាវ និងសក្តិចុងដៃអាវ ពណ៌មាស ឬ ប្រាក់ ប្រើទៅតាមឋានន្តរសក្តិ ។

-ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅមានចងខ្សែ និងស្រោមជើងពណ៌ខ្មៅ សំរាប់ប្រើគ្រប់ឋានន្តរសក្តិ ។

-អាវសឺមីពណ៌ស កឌុប និង ក្រវ៉ាត់កពណ៌ខៀវចាស់តាមគំនូររូបភាពដូចគ្នា សំរាប់ គ្រប់ឋានន្តរសក្តិ ។

**២._ចំពោះស្ត្រី :**

-មានអាវវ៉ារីដូចបុរសដែរ តែអាវនេះមានសម្រុងចុះពីក្រោមចង្កេះប្រវែង ២០ សង្ទីម៉ែត្រ .

-សំពត់ហ្សីបបត់ពណ៌ស មានសម្រុងលើភ្នែកគោល នៃស្មងជើងប្រវែងពី ១០ទៅ ១៥ សង្ទីម៉ែត្រ អនុលោមទៅតាមមាឌ និងកំពស់ ។

-ស្បែកជើង ឃ្លុបមុខ ឃ្លុបក្រោយ ពណ៌ស ឬពណ៌ខ្មៅ ។

រូបគំនូរឯកសណ្ឋានផ្លូវការសំរាប់បុរស និងស្ត្រី មានគំរូដូចក្នុងឧបសម្ព័ន្ធទី១៥ នៃព្រះរាជក្រឹត្យនេះ ។

**ខ-ឯកសណ្ឋានប្រពៃណីជាតិ**

**១-ចំពោះបុរស :**

-អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំ មានសន្ទះលើស្មាសំរាប់ដាក់សក្តិ និងគ្មានផែកខ្នង . អាវនេះ មានហោប៉ៅចំនួន ០៤ គឺហោប៉ៅខាងលើពីរដេរប៉ះចំកណ្តាល ចាប់ផ្នត់មួយមានគំរបរាងស្លឹកពោធិហោប៉ៅខាងក្រោមពីរដេរបង្កប់ មានគំរបរាងចតុកោណកែង " ហើយនៅលើគំរបហោប៉ៅ ទាំងបួននោះមានឡេវរូបព្រះរាជសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរសក្តិ . នៅចុងដៃអាវ ទាំងសងខាងមានឡេវបញ្ជោតរូបព្រះរាជសង្ហារពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរសក្តិ . អាវកុដពណ៌សនេះមានឡេវរូបព្រះរាជសង្ហារ ចំនួន ០៧ ពណ៌មាស ឬពណ៌ប្រាក់ទៅតាមឋានន្តរសក្តិ ។

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

-ស្បែកជើងឃ្លុប កខ្លី ពណ៌ខ្មៅ មានចងខ្សែ ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

**២-ចំពោះស្ត្រី :**

-សំពត់ហូលសំឡុយ ពាក់ជាមួយអាវប៉ាក់ ដៃខ្លី ( លើកែងដៃ ) មានកមូល ។

-សំពត់ផាមួង ចងក្បិន ពណ៌តាមថ្ងៃ ពាក់ជាមួយអាវប៉ាក់ ដៃវែង មានកមូល ។

-ពានាក្រមាពណ៌តាមសំពត់ ឬ ពានាក្រមាពណ៌ស៊ីន្ទូន ( តាមពិធីការកំណត់ ) ។

នៅលើក្រមាពានាផ្នែកខាងឆ្វេង នៃដើមទ្រូង មានខ្ទាស់សញ្ញាសំគាល់ ទៅតាមឋានន្តរសក្តិផង ។

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ ពណ៌ស ឬ ពណ៌ខ្មៅ ។

-កាបូបយួរដៃ ពណ៌ស ឬ ពណ៌ខ្មៅ ( មិនអោយស្ពាយទេ ) ។

រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសំរាប់បុរស និងស្ត្រី ដែលស្លៀកសំពត់ផាមួងចងក្បិន មានគំរូដូចក្នុងឧបសម្ព័ន្ធទី១៦ និងរូបគំនូរឯកសណ្ឋានប្រពៃណីជាតិស្ត្រី ដែលស្លៀកសំពត់ហូល ឬ ផាមួង សំឡយ មានគំរូដូចក្នុងឧបសម្ព័ន្ធទី១៧ នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ៥ ._**

ការប្រើប្រាស់ឯកសណ្ឋាន សំរាប់មន្ត្រីក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ និងមន្ត្រីក្របខ័ណ្ឌមន្ត្រីក្រមការ នៃក្រសួងមហាផ្ទៃ ត្រូវបានកំណត់ដូចខាងក្រោម :

-ឯកសណ្ឋានផ្លូវការ សំរាប់ប្រើប្រាស់ក្នុងឱកាសទិវាបុណ្យជាតិ និងពិធីផ្លូវការផ្សេងៗ ។

-ឯកសណ្ឋានប្រពៃណីជាតិ សំរាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និងសាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ក្នុងវត្តអារាម និងទីកន្លែងផ្សេងៗ ។

## ជំពូកទី ៤

## របបកំណត់ឯកសណ្ឋាន និងសញ្ញាសក្តិ

**មាត្រា ៦ ._**

ត្រូវបានផ្តល់ជូនដល់មន្ត្រីម្នាក់ៗ នូវឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ មួក សញ្ញាសក្តិ និងសំភារៈផ្សេងៗទៀត ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ មួយសម្រាប់ សំរាប់ប្រើប្រាស់រយៈពេលបីឆ្នាំ ។

## ជំពូកទី ៥

## អវសានប្បញ្ញត្តិ

**មាត្រា ៧ ._**

បទប្បញ្ញត្តិ ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨ .-**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០០១

ព្រះហស្តលេខា

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

សូមចុះហត្ថលេខា

សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ

ហត្ថលេខា

**ស ខេង យូ ហុកគ្រី**

សំរាប់ថ្នាក់ផ្កាយសក្តិ ឧត្តមមន្ត្រី (ពណ៌មាស)

ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/
០៥៩ ចុះថ្ងៃទី ៨ មីនា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ
របស់... នៃមន្ត្រីក្របខ័ណ្ឌ មន្ត្រីនគរបាលជាតិ
... នៃមន្ត្រីក្របខ័ណ្ឌ មន្ត្រីនគរបាលរដ្ឋបាល



មួកការស្កេត

# សំរាប់ឋានន្តរសក្តិ ឧត្តមមន្ត្រី (ពណ៌មាស)

[illegible] នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/
០៤៩ ចុះថ្ងៃទី ៨ ខែ មីនា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ
[illegible] នៃមន្ត្រីក្របខ័ណ្ឌ មន្ត្រីរដ្ឋបាលជាន់
[illegible] និងមន្ត្រីក្របខ័ណ្ឌ មន្ត្រីក្រមការក្រសួងមហាផ្ទៃ



មួកកាស្កេត

[illegible]



[illegible]

## សញ្ញាសក្តិ មន្ត្រីឋានន្តរសក្តិឧត្តមមន្ត្រី



សក្តិកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

សញ្ញាសក្តិ មន្ត្រីឋានន្តរសក្តិវរៈមន្ត្រី



សញ្ញាសក្តិ មន្ត្រីឋានន្តរសក្តិអនុមន្ត្រី



សក្តិករអាវ



សក្តិប៉ានស្មា



សក្តិចុងដៃអាវ

**សក្តិខ្ទាស់លើដើមស្មា សំរាប់អាវ**
**សំរាប់ក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ (ពណ៌មាស)**

សំរាប់ឋានន្តរសក្តិ ឧត្តមមន្ត្រី



សំរាប់ឋានន្តរសក្តិ វរៈមន្ត្រី



សំរាប់ឋានន្តរសក្តិ អនុមន្ត្រី



[illegible] នស/រកត/០៣០១/០៤៥
[illegible] ៨ មីនា ២០០១ [illegible]
[illegible]

មួកការស្ពត សំរាប់មន្ត្រីជាន់ខ្ពស់ នាយក្រុមគោះ



មុខ

នស/រកត/០៣០៧/៤៥
ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ២០០១



មួកកាស្កេត សំរាប់មន្ត្រីឋានន្តរសក្តិ ក្រមការ

ឧបសម្ព័ន្ធទី ១០ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/៤៩
ចុះថ្ងៃទី ៨ ខែមីនា ឆ្នាំ ២០០១ ស្ដីពីសញ្ញាសក្ដិ
នៃមន្ត្រីក្របខ័ណ្ឌ មន្ត្រីជាន់ខ្ពស់
មន្ត្រីក្របខ័ណ្ឌ មន្ត្រីក្រមការ



ម្ភៃ

# សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិនាយក្រមការ



សក្តិករអាវ



សក្តិប៉ានស្មា



សក្តិចុងដៃអាវ

...លេខ នស/រកត
... ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ

# សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិក្រមការដើមខ្មែរ



សក្តិករអាវ



សក្តិប៉ានស្មា



សក្តិចុងដៃអាវ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិក្រមការ



សក្តិករអាវ



សក្តិបិនស្មា



សក្តិចុងដៃអាវ

## សក្តិខ្នាស់លើដើមស្មា សំរាប់នារី
## សំរាប់ក្រុមខំណាមន្ត្រីក្រុមការ (ពណ៌ប្រាក់)

សំរាប់ថ្នាក់ផ្កាសក្តិ នាយក្រុមការ



សំរាប់ថ្នាក់ផ្កាសក្តិ ក្រុមការដើមខ្សែ



សំរាប់ថ្នាក់ផ្កាសក្តិ ក្រុមការ



ឧបសម្ព័ន្ធទី១៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៣០១/០៤៩
ចុះថ្ងៃទី៨ ខែមីនា ឆ្នាំ ២០០១ ស្តីពីសញ្ញាសក្តិ

រូបគំរូឯកសណ្ឋានផ្លូវការ សំរាប់បុរស និងស្ត្រី



**រូបគំរូឯកសណ្ឋានប្រពៃណីជាតិ សំរាប់បុរស និងស្ត្រី**



[illegible] ០៤៩ ចុះថ្ងៃទី ៨ ខែមីនា [illegible] ២០០១ [illegible]



# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ២៦ អនក្រ.បក

### ស្តីពីការបង្កើតនិងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ។បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០០

### សំរេច

**មាត្រា ១ .-**

អនុញ្ញាតអោយបង្កើតភ្នាក់ងារសុខភាពសត្វភូមិ ក្នុងគោលបំណងបង្កើតមុខរបរសំរាប់ប្រជាពលរដ្ឋ និងបង្កើនផលិតភាព និង គុណភាពសត្វ អោយសមស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលស្តីពីឯកជនភាវូបនីយកម្ម ក្នុងវិស័យផលិតកម្ម និងបសុព្យាបាល សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រនៅជនបទ ។

**មាត្រា ២ .-**

ភ្នាក់ងារសុខភាពសត្វភូមិនេះ មិនត្រូវជាភ្នាក់ងាររដ្ឋទេ គឺជាភ្នាក់ងារដែលត្រូវជ្រើសរើសក្នុងចំណោមប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ឬ សិស្ស-និស្សិតដែលបានទទួលការបណ្តុះបណ្តាល មកទទួលការបណ្តុះបណ្តាល និងបំពាក់បំប៉នបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣ .-**

នីតិវិធីនៃការជ្រើសរើស ការបណ្តុះបណ្តាល ការទ្រទ្រង់សកម្មភាព ការគ្រប់គ្រងអោយមាននិរន្តរភាព តួនាទី និងភារកិច្ចរបស់ភ្នាក់ងារសុខភាពសត្វភូមិ និងគោលការណ៍ពាក់ព័ន្ធដទៃទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៤ .-**

បទប្បញ្ញត្តិដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ២៧ អនក្រ.បក

## ស្តីពីការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទ ខេត្តព្រៃវែង ទុកសំរាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យ ជលផល
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សម្រេច**

**មាត្រា ១ .-**

ត្រូវបានកែសំរួលប្រកាសលេខ ០០៤០ ប្រក.កសក ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តព្រៃវែង ដូចតទៅ :

-លុបចេញនាទីឡូត៍នេសាទលេខ ៧. ៨.១២.៩.១៦ និងលេខ ១៧ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។

-កាត់ចេញពីនាទីឡូត៍នេសាទនៃផ្ទៃដែននេសាទក្នុងខេត្តព្រៃវែង និងកំណត់ព្រំប្រទល់ឡូត៍នេសាទជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តព្រៃវែង ដែលត្រូវលុប និងកាត់បន្ថយ

ឯកតា ( ហិកតា )

| ប្រភេទ និង លេខឡូត៍ | ផ្ទៃឡូត៍ នេសាទ | ផ្ទៃឡូត៍ កាត់ចេញ | ផ្ទៃឡូត៍ នៅសល់ | ផ្ទៃឡូត៍កាត់ គិតជាភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|
| បឹងព្រែក | | | | | |

| | | | | | |
|---|---|---|---|---|---|
| ១ | ១១.៣៦៨ | ៥.០៥៩ | ៦.៣០៩ | ៤៤.៥០ | |
| ២ | ១៧.៥២៦ | ៧.២៥១ | ១០.២៧៥ | ៤១.៣៧ | |
| ៣ | ៥.២០១ | ៣.៨៥៣ | ១.៣៤៨ | ៧៤.០៨ | |
| ៤ | ៦.២៣៣ | ២.៥៤២ | ៣.៦៩១ | ៤០.៧៨ | |
| ៥ | ៥.២៧៩ | ៣.២២២ | ២.០៥៧ | ៦១.០៣ | |
| ៦ | ១៤.៣១៨ | ១១.៨០០ | ២.៥១៨ | ៨២.៤១ | |
| ៧ | ២.៦២៣ | ២.៦២៣ | ០ | ១០០ | លុបចេញ |
| ៨-១២ | ៨.៥១៨ | ៨.៥១៨ | ០ | ១០០ | លុបចេញ |
| ៩ | ១៤.២៦៩ | ១៤.២៦៩ | ០ | ១០០ | លុបចេញ |
| ១០ | ២០.២៧៨ | ១២.៧៧០ | ៧.៥០៨ | ៦២.៩៧ | |
| ១១ | ២.៩៦៥ | ២.២៩៦ | ៦៦៩ | ៧៧.៤៣ | |
| ១៣ | ៥.៤៣១ | ១.៩២៦ | ៣.៥០៥ | ៣៥.៤៦ | |
| ១៤ | ២.៧២៣ | ១.១១១ | ១.៦០២ | ៤០.៥៥ | |
| ១៥ | ៣.៥២៦ | ៦១២ | ២.៩១៤ | ១៧.៣៥ | |
| ១៦ | ៤.៥១៨ | ៤.៥១៨ | ០ | ១០០ | លុបចេញ |
| ១៧ | ៣.១៣៣ | ៣.១៣៣ | ០ | ១០០ | លុបចេញ |
| ១៨ | ៤.៩៧៤ | ៦៥៨ | ៤.៣១៦ | ១៣.២២ | |
| ១៩ | ២.៧៣៥ | ១.១៥៩ | ១.៥៧៦ | ៤២.៣៧ | |
| ២០ | ៧.៤៦១ | ៤០៩ | ៧.០៥២ | ៥.៤៨ | |
| សរុប ១៩ | ១៤៣.០៦៩ | ៨៧.៧២៩ | ៥៥.៣៤០ | ៦១.៣១ | |

**មាត្រា ២ ..**

ដែននេសាទដែលបានលុបចេញ និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូនប្រជាពលរដ្ឋប្រកបរបរនេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុំហួងហែងយកទៅលក់ ឬជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

**មាត្រា ៣ ._**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមណ៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទនេះ ។

**មាត្រា ៤ ._**

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលមានការពាក់ព័ន្ធ និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្តតាមអនុក្រឹត្យនេះតាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រាជធានីភ្នំពេញ . ថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១**

**នាយករដ្ឋមន្ត្រី**

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ៩២ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**សំរេច**

**មាត្រា ១ .-** ត្រូវបានតែងតាំងលោក **កែម សេន** ជាប្រធាននាយកដ្ឋានគ្រឿងយន្តកសិកម្ម នៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ៩៣ អនក្រ.តត**

**ស្តីពីការដូរមេដាយ មុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៦៩៩/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

**សម្រេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ប្រគេនជូនព្រះសង្ឃ អាចារ្យវត្ត ចំនួន ០៥រូបដែលបានខិតខំ ប្រឹងប្រែងយកកំលាំងកាយពលចូលរួមកសាងព្រះវិហារ សុវណ្ណមុនីវង្ស ស្ថិត នៅក្នុងសង្កាត់ ឃ្មួញ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយនាមជូនខាងក្រោម ៖

**ក.មេដាយមុនីសារាភ័ណ្ឌថ្នាក់សេនា**

-ព្រះតេជគុណ **យ៉ែម សុខ្ន**

**ខ.មេដាយមុនីសារាភ័ណ្ឌថ្នាក់អស្សរិទ្ធ**

-ព្រះតេជគុណ **ប៊ិន ខេម**

-ព្រះតេជគុណ **គិន សុផាត**

-ព្រះតេជគុណ **សោខ ប៊ុន្នី**

-លោកតា **ឃិន ខាន់**

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ៩៤ អនក្រ.តត

## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

## រាជរដ្ឋាភិបាល,

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ១៥ រូបដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមកសាងព្រះវិហារ វត្តសុវណ្ណមុនីវង្ស ស្ថិតនៅសង្កាត់ឃ្មួញ ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ដូចមានរាយនាមជូនខាងក្រោម :

| | | | |
|---|---|---|---|
| ១-ព្រះតេជគុណ | **អ៊ុង** | **ស៊ុណសាត** | ២៥.៧០០ USD |
| ២-ឯកឧត្តម | **អ៊ុក** | **ជាម៉ី** | ២៨.៣០០ USD |
| ៣-ឯកឧត្តម | **ហ៊ីង** | **ប៊ុនហៀង** | ២៦.៥០០ USD |
| ៤-លោកជំទាវ | **ម៉ែន** | **ចន្ធី** | ២៤.៥០០ USD |
| ៥-លោក | **ហែម** | **ថេង** | ២៣.៥០០ USD |
| ៦-លោក | **លី** | **ប៊ុន** | ២០.០០០ USD |
| ៧-លោក | **វស់** | **ម៉ុំ** | ២០.០០០ USD |
| ៨-លោក | **ពន** | **ច្រិក** | ១៦.៨១៦ USD |
| ៩-ឧបាសិកា | **សុខ** | **ឡាង** | ១៦.៦៥៣ USD |

១០-ឧបាសិកា **ឈើ ស៊ុខ** ១៥.៨០០ USD

១១-ឧបាសិកា **តាន់ ស៊ុយង៉ែង** ១៦.០០០ USD

១២-អ្នកស្រី **ពឹង ឆចេង** ១៥.៣០០ USD

១៣-លោក **មិត្ត ស៊ីធួន** ១៤.០០០ USD

១៤-លោក **ពត ទង** ១៣.០០៨ USD

**មាត្រា ២ ..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ត្រូវអនុវត្តនូវ អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ៩៥ អនក្រ.តត

## ស្តីពីការជូនមេដាយ មុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សរិទ្ធ** ប្រគេនព្រះតេជគុណចៅអធិការ **ខេ សុខណ្ណត្ថ** ដែលបានខិតខំប្រឹងប្រែងយកអស់កំលាំងកាយពល ចូលរួមកសាងព្រះវិហារ ដងទង់ របងវត្ត និងចាក់ដីបំពេញបន្ថែមវត្តសិរីជ័យមង្គល ហៅវត្តតាគោហ៊ ស្ថិតនៅឃុំរកាកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាលត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ . ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ៩៦ អនក្រ.តត
## ស្តីពីការជូនមេដាយ ស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០១៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសអោយប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ អភិបាលខេត្តកណ្តាល

## សំរេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ជូនសប្បុរសជនចំនួន ០៨ រូប ដែលបានចូលរួម កសាងព្រះវិហារ ដងទង់ របងវត្ត និងចាក់ដីបំពេញបន្ថែមវត្តសិរីជ័យមង្គល ហៅវត្តតាគោហ៊ៅស្ថិតនៅ ក្នុងឃុំរការកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម ៖

**ក.មេដាយមាសស្ថាបនាជាតិ ៖**

១-ឯកឧត្តមអ្នកឧកញ៉ា **ចក់ ឡេង** ថវិកា ៥០.៥០០ USD

២-លោកជំទាវ **ខៀវ ហុង** ថវិកា ១៨.០០០ USD ២៧.០០០.០០០ រៀល និងមាស ៣ ជីឡឹង

៣-លោកវរសេនីយ+ឯក **ចេង ចាន់តុង** ថវិកា ១០.២០០ USD

៤-លោកវរសេនីយ+ទោ **សារ៉ាយ ឆុន** ថវិកា ១២.០០០ USD

**ខ.មេដាយប្រាក់ស្ថាបនាជាតិ ៖**

១-លោកវរៈសេនីយ+ឯក **ឆេងអ៊ី វីណារុទ្ធ** ថវិកា ៥.២០០ USD

២-លោកវរៈសេនីយ+ទោ **ង៉ូ សារុធ** ថវិកា ៥.០០០ USD

៣-លោកវរៈសេនីយ+ទោ **គីម វាសនា** ថវិកា ៥.០០០ USD

៤-លោក **ឡេង ឡុង** ថវិកា ៥.០០០ USD

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ៩៧ អនក្រ.តត
# ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងពត៌មាន
- យោងតាមសំណើរបស់ក្រសួងពត៌មាន

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងមន្ត្រីចំនួន ០៤ រូប នៃទីភ្នាក់ងារសារពត៌មានកម្ពុជា " AKP " នៃក្រសួងពត៌មាន ដែលមានរាយនាមដូចខាងក្រោម :

១-លោក **នុត ឈឿន** ជាប្រធាននាយកដ្ឋាន កាសែតកម្ពុជា

២-លោក **នាត់ សាវរ៉ាត** ជាប្រធាននាយកដ្ឋាន ទស្សនាវដ្តី

៣-លោក **រស់ ណារិទ្ធ** ជាប្រធាននាយកដ្ឋាន បច្ចេកទេស និងបោះពុម្ពផ្សាយ

៤-លោក **ចាន់ សាវ៉ាត** ជាប្រធាននាយកដ្ឋានពត៌មានក្នុង និង ក្រៅប្រទេស

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់

ក្រសួងស្ថាប័នពាក់ព័ន្ធនិងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ ខាងលើត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ៩៨ អនក្រ.តត**

**ស្តីពីការជូនមេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តតាកែវ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក ឧកញ៉ា **កែវ ឡា** នាយកក្រុមហ៊ុន ស ។ឡាគ្រុប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ចំនួន ១២ ។៦៤២ ដុល្លារអាមេរិក ដើម្បីកសាងអាគារ សិក្សា មួយខ្នងបំពាក់គ្រឿងសង្ហារឹមគ្រប់ចំនួន នៅសាលាបឋមសិក្សាមង្គល-គីរី ឃុំ ព្រៃរំដេង ស្រុកគីរីវង់ ខេត្តតាកែវ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ៩៩ អនក្រ.តត**

**ស្តីពីការប្រគល់មេដាយស្ថាបនាជាតិ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- **បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី**
- **បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥** ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

**សំរេច**

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនតំណាងក្រុមហ៊ុន **ការហ្វជូធំរ** សប្បុរសជន ជប៉ុន ដែលបានជួយកសាងអាគារសិក្សា ០២ ខ្នង មាន១០ បន្ទប់ នៅសាលាបឋមសិក្សាចង្ហោច ឃុំព្រៃកន្តោត ស្រុកកំពត ខេត្តកំពត គិតជាទឹកប្រាក់សរុបចំនួន ៥១.៥៨២ ដុល្លារអាមេរិក ( ហាសិបមួយពាន់ប្រាំរយប៉ែតសិបពីរដុល្លារ ) ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ១០០ អនក្រ.បក
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពត

## សំរេច

**មាត្រា ១ .-** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនតំណាង **សហជីពកម្មករអាជីណូម៉ូតូ** សប្បុរសជនជប៉ុន ដែលបានជួយកសាងអាគារសិក្សា ០១ខ្នង មាន០៥ បន្ទប់នៅសាលាបឋមសិក្សា ម៉ាក់ប្រាង្គ ឃុំម៉ាក់ប្រាង្គ ស្រុកកំពត ចំណាយថវិកាអស់ ១៥.៧៩១ ដុល្លារអាមេរិក ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## អនុក្រឹត្យលេខ ១០១ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ៦៧/អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- យោងតាមសំណើរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និអធិការកិច្ច

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងលោក **ហួត ហាក់** ជាប្រធាននាយកដ្ឋានរដ្ឋបាល- បុគ្គលិក នៃក្រសួងទំនាក់ ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ២.-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**អនុក្រឹត្យលេខ ១០២ អនក្រ.តត**

**ស្តីពីការតែងតាំងមន្ត្រីរាជការ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៥ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
- បានឃើញអនុក្រឹត្យលេខ ៦៧/អនក្រ.បក ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

- យោងតាមសំណើរបស់ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

**សំរេច**

**មាត្រា ១ .-** ត្រូវបានតែងតាំងលោកស្រី **សូ ណារ៉េន** ជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ នៃក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ។

**មាត្រា ២.-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

## ២.សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០១

### សេចក្តីសំរេចលេខ ១១ សសរ

### ស្តីពីការបង្កើតគណៈកម្មការចំរុះ នៃកិច្ចសហប្រតិបត្តិការកម្ពុជា ឥណ្ឌូនេស៊ី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងស្មារតីនៃកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលកម្ពុជានិងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌូនេស៊ី ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងបច្ចេកទេស ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ១៩៩៤ នៅក្រុងហ្សាកាតា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ចុះថ្ងៃទី ២០ ខែ កុម្ភៈ ខែ ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១** : បង្កើតគណៈកម្មការចំរុះ នៃកិច្ចសហប្រតិបត្តិការ កម្ពុជា ឥណ្ឌូនេស៊ី ដែលមានសមាសភាពដូច តទៅ :

| | |
|---|---|
| ១-រដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២-តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥-តំណាងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា | សមាជិក |
| ៦-តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | សមាជិក |
| ៧-តំណាងក្រសួងទេសចរណ៍ | សមាជិក |
| ៨-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៩-តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ១០-តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១១-តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១២-តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៣-មន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | លេខាប្រតិបត្តិ |

**ប្រការ ២** : គណៈកម្មការចំរុះនេះ មានបេសកកម្ម ដូចខាងក្រោម :

-ពិនិត្យការអនុវត្តន៍កិច្ចព្រមព្រៀង និងពិភាក្សាបញ្ហាទាំងឡាយ ដែលអាចកើតមានឡើងពីការអនុវត្តកិច្ចព្រមព្រៀងនេះ ហើយនិងបង្កើតអនុសាសណ៍សំខាន់ៗទាំងឡាយ ដើម្បីសំរេចគោលដៅរបស់ខ្លួន ។

-គណៈកម្មការចំរុះនេះ នឹងជួបប្រជុំគ្នាជាមួយគណៈកម្មការ ខាងភាគីឥណ្ឌូនេស៊ី តាមពេលវេលាសមស្រប ដោយមានការព្រមព្រៀងគ្នាជាមុន ។

**ប្រការ ៣** : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារកិច្ច និងសិទ្ធិ :

-សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំឯកសារកម្មវិធីនៃសកម្មភាព ក្នុងការគ្រប់គ្រង និងជំរុញកិច្ចសហប្រតិបត្តិការ ក្នុងទិសដៅអភិវឌ្ឍណ៍សេដ្ឋកិច្ចនិងបច្ចេកទេសរវាងកម្ពុជា និង ឥណ្ឌូនេស៊ី ។

-ចូលរួមប្រជុំ និងធ្វើទំនាក់ទំនងផ្ទាល់ ជាមួយក្រុមការងារសហប្រតិបត្តិការសេដ្ឋកិច្ច និងបច្ចេកទេស ខាងភាគីឥណ្ឌូនេស៊ី និងអង្គការអន្តរជាតិនានា ដើម្បីដោះស្រាយការងារពាក់ព័ន្ធ ។

-បង្កើតប្រតិទិនប្រចាំឆ្នាំមួយ សំរាប់អនុវត្តគំរោងផែនការ ដែលរដ្ឋាភិបាលនៃភាគីទាំងពីរបានឯកភាពគ្នា ។

-ធ្វើរបាយការណ៍អំពីលទ្ធផលការងារ ជូនរាជរដ្ឋាភិបាល ដើម្បីសុំមតិណែនាំ និងគោលការណ៍សំរេច ។

-ក្នុងករណីចាំបាច់ គណៈកម្មការចំរុះនេះ អាចបង្កើតក្រុមការងារ និងតែងតាំងអ្នកជំនាញការ ឬទីប្រឹក្សា ដើម្បីចូលរួមប្រជុំ ។

**ប្រការ ៤** : សមាជិកនៃគណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញនិងក្រោមការដឹកនាំ របស់ប្រធានគណៈកម្មការ ឬអនុប្រធាន ក្នុងករណីអវត្តមានរបស់ប្រធាន ។ ក្នុងករណីសមាជិក [illegible] មិនបានចូលរួមប្រជុំ ដោយជាប់រវល់ភារកិច្ច ត្រូវចាត់តំណាងដែលមានសិទ្ធិសំរេច អោយចូល [illegible] ប្រជុំជំនួស ។

**ប្រការ ៥** : គណៈកម្មការចំរុះ នៃកិច្ចសហប្រតិបត្តិការកម្ពុជា ឥណ្ឌូនេស៊ី មានលេខាធិការដ្ឋាន ដែលមានទីតាំងនៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ហើយមានសិទ្ធិប្រើប្រាស់ត្រា របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងករណីចាំបាច់ និងមានសិទ្ធិអញ្ជើញអ្នកជំនាញឯកទេស

មកពីគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធអោយចូលរួមប្រជុំ ឬ ជួយបំពេញការងារ ក្នុងឋានៈជាជំនួយការបច្ចេកទេស ។ លេខាធិការដ្ឋាន នៃគណៈកម្មការចំរុះ កម្ពុជា ឥណ្ឌូនេស៊ី ត្រូវដឹកនាំដោយ អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មការចំរុះនេះ ។

**ប្រការ ៦ :** គ្រប់ក្រសួង និង ស្ថាប័នពាក់ព័ន្ធ ដែលមានសមាសភាពនៃគណៈកម្មការចំរុះ ដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវចាត់តាំងនិងបញ្ជូនឈ្មោះមន្ត្រីរបស់ខ្លួន ទៅក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អោយបានរួសរាន់ សំរាប់ការអនុវត្តន៍សកម្មភាពរបស់គណៈកម្មការនេះ ។

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

រាជធានីភ្នំពេញ , ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

## សេចក្តីសំរេចលេខ ១២ សសរ

## ស្តីពីការបង្កើតគណៈកម្មាធិការជាតិត្បូងថ្មកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើចាំបាច់របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មាធិការជាតិធ្យូងថ្មកម្ពុជា ដែលមានសមាសភាព ដូច តទៅ :

១-ឯកឧត្តម **សូច ជ័ចគុណា** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ប្រធាន

២-លោក **សាត សារ៉ា** ប្រធាននាយកដ្ឋានបច្ចេកទេសថាមពលនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៣-លោក **ឃុន បញ្ញាសិដ្ឋ** ប្រធាននាយកដ្ឋានអភិវឌ្ឍណ៍ធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៤-លោក **សុខ ឡេង** ប្រធាននាយកដ្ឋានធនធានរ៉ែនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៥-លោក **ហង្ស ម៉ឺន** អនុប្រធាននាយកដ្ឋានត្រួតពិនិត្យទំនិញនីហរណ៍ អាហរណ៍ និងបង្ក្រាប ការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម សមាជិក

៦-លោក **សៀង សុខចាម** ប្រធានការិយាល័យភូគព្ភសាស្ត្រ នាយកដ្ឋានភូគព្ភសាស្ត្រ នៃក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល សមាជិក

៧-លោក **នៅ សួស្តី** មន្ត្រីនាយកដ្ឋានអាស៊ាននៃទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

**ប្រការ ២ :** គណៈកម្មាធិការជាតិធ្យូងថ្មកម្ពុជា មានតួនាទីសំរបសំរួល និងសហការជាមួយវេទិកាអាស៊ានសំរាប់ធ្យូងថ្ម ( ASEAN FORUM ON COAL ) បណ្តាក្រសួង ស្ថាប័នមានសមត្ថកិច្ច ខេត្ត-ក្រុងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ ក្រុមហ៊ុនឯកជន ដើម្បីជំរុញការសិក្សាស្រាវជ្រាវអភិវឌ្ឍណ៍ និងប្រើប្រាស់រ៉ែធ្យូងថ្មអោយមាន ប្រសិទ្ធភាព និងរក្សាការពារបរិស្ថាន ។

**ប្រការ ៣ :** គណៈកម្មាធិការជាតិធ្យូងថ្មកម្ពុជា មានភារកិច្ច :

-រៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការ សំរាប់ការអភិវឌ្ឍន៍ និងគោលការណ៍ប្រើប្រាស់ រ៉ែធ្យូងថ្មនៅព្រះរាជាណាចក្រកម្ពុជា ។

-គោរពនិងអនុវត្តតាមភារកិច្ចដែលមានកំណត់ក្នុងធម្មនុញ្ញ. ស្តីពីវេទិកាអាស៊ានសំរាប់ធ្យូងថ្ម ( CHARTER ON ASEAN FORUM ON COAL ) ។

-ចុះហត្ថលេខាលើឯកសារជាផ្លូវការមួយចំនួនក្រោយពីបានទទួលសិទ្ធិប្រទានពីប្រមុខរាជរដ្ឋាភិបាល ។

-ធ្វើរបាយការណ៍អោយបានទៀងទាត់ ជូនរាជរដ្ឋាភិបាលអំពីសកម្មភាព និងលទ្ធផល ដែលសំរេចបាន ។

**ប្រការ ៤ :** គណៈកម្មាធិការជាតិធ្យូងថ្មកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រង និងទទួលខុសត្រូវរបស់ប្រធាន ។

**ប្រការ ៥ :** សមាជិកគណៈកម្មាធិការ ត្រូវចូលរួមប្រជុំពិភាក្សាការងារតាមការអញ្ជើញរបស់ប្រធាន .

**ប្រការ ៦ :** គណៈកម្មាធិការនេះ មានលេខាធិការដ្ឋានមួយប្រចាំនៅអគ្គនាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ព្រមទាំងបណ្តាក្រសួង ស្ថាប័ន ខេត្ត ក្រុង ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ ចាប់ពី ថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០១

**សេចក្តីសំរេចលេខ ១៣ សសរ**

**ស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង**

**ដើម្បីស្រាវជ្រាវត្រួតពិនិត្យប្រមូលព័ត៌មានជុំវិញបញ្ហាផ្សារម៉ីងឈូក**

**និងបញ្ហាដេញថ្លៃភាស៊ីស្តង់ត្រីស្រស់នៅខេត្តបាត់ដំបង**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- ផ្អែកតាមមតិណែនាំរបស់សម្តេចនាយករដ្ឋមន្ត្រី
- ផ្អែកតាមសំណូមពរការងារចាំបាច់

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មការចំរុះអន្តរក្រសួងមួយ ដែលមានសមាសភាពដូច តទៅ :

១-លោក **គុល វីរត្ន** តំណាងក្រសួងមហាផ្ទៃ ជាប្រធាន

២-ឯកឧត្តម **យិន គីមស៊ាន** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី ជាអនុប្រធាន

៣-លោក **ភាំង លាងខ័ណ្ឌ** តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសមាជិក

៤-លោក **ហួត វុទ្ធី** តំណាងក្រសួងយុត្តិធម៌ ជាសមាជិក

៥-លោក **ហួយ គីមឡុនៈ** តំណាងក្រសួងមហាផ្ទៃ ជាសមាជិក

៦-លោក **ស៊ុន សុខន** តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាសមាជិក

**ប្រការ ២ :** គណៈកម្មការដូចកំណត់ក្នុងប្រការមួយមានភារកិច្ចស្រាវជ្រាវ ត្រួតពិនិត្យប្រមូលពត៌មាន សំរាប់ដាក់ជូន និង សុំសេចក្តីសំរេចដ៏ខ្ពង់ខ្ពស់ អំពីរាជរដ្ឋាភិបាល ។

**ប្រការ ៣ :** គណៈកម្មការមានសិទ្ធិចាត់តាំងក្រុមជំនួយការ ដើម្បីជួយសំរួលការងារក្នុងករណីចាំបាច់ ។

**ប្រការ ៤ :** គណៈកម្មការមានសិទ្ធិធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរ និង អង្គភាព ផ្សេងៗ ដែលពាក់ព័ន្ធ ដើម្បីបំពេញការងារអោយមានប្រសិទ្ធភាព ។

**ប្រការ ៥ :** រាល់មធ្យោបាយ និងថវិកាសំរាប់ធ្វើការក្នុងកិច្ចការនេះ សាមីក្រសួងនីមួយៗជាអ្នកទទួល បន្ទុក ដោះស្រាយដើម្បីអោយមន្ត្រីក្រោមឱវាទដែលមានឈ្មោះដូចក្នុងប្រការ១ មានលទ្ធភាពគ្រប់ គ្រាន់ក្នុងការអនុវត្តន៏ការងារ ។

**ប្រការ ៦ :** សេចក្តីសំរេចណាដែលមានន័យផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួង ប្រធានស្ថាប័នដែល ពាក់ព័ន្ធ និងឯកឧត្តម អស់លោកដូចក្នុងប្រការ១ មានភារកិច្ចទទួលអនុវត្តតាមស្មារតីនៃសេចក្តីសំរេច នេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស ខេង**

## III- ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មីនា ឆ្នាំ ២០០១

**ប្រកាសលេខ ១៦៥ ឧរថគឧ ។ប្រក**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ។បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ១៨៦០/០០ គ.វ.ក ចុះថ្ងៃទី ០៤-៧-២០០០ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៧៨៨ ប.ស្ត.ស.ណ ចុះថ្ងៃទី ០១-៨-២០០០ របស់ក្រសួងបរិស្ថាន
- បានឃើញកិច្ចសន្យាជួលរោងចក្រតម្បាញកំពង់ចាម រវាងក្រុមហ៊ុន MANHATTAN TEXTILE AND GARMENT CORP និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៩
- យោងពាក្យស្នើរបស់ក្រុមហ៊ុន លៀន អ៊ីតិចថាយ ( ខេមបូឌា ) ខូអិលធីឌី ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ២០០១

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន លៀន អ៊ី តិចថាយ (ខេមបូឌា) ខូអិលធីឌី "LIEN-I TEXTILES ( CAMBODIA) CO ; LTD " តំណាងដោយលោក LIN CHAO HSIN សញ្ជាតិ ចិន (តៃវ៉ាន់) ភេទ ប្រុស អាយុ ៤៤ ឆ្នាំ កាន់លិខិតឆ្លងដែនលេខ M 20118455 ចុះថ្ងៃទី 02-6-98 បង្កើត "រោងចក្រតម្បាញ និងចាក់សំលៀកបំពាក់ "ដែលមានផ្លាកឈ្មោះថា" លៀន អ៊ីតិចថាយ (ខេមបូឌា) ខូ អិលធីឌី "មានទីតាំងស្ថិតនៅក្នុងបរិវេណ អតីតរោងចក្រតម្បាញកំពង់ចាម ទីរួមខេត្តកំពង់ចាម ។

**ប្រការ ២ :** ក្រុមហ៊ុនត្រូវរៀបចំចក្រទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៣ :** រោងចក្រនេះត្រូវបានអនុញ្ញាតអោយ " តម្បាញក្រណាត់ និង ចាក់សំលៀកបំពាក់ " ហើយត្រូវធ្វើ របាយការណ៍ប្រចាំខែអំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៤ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅ ពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៥ :** ការពង្រីកផលិតកម្ម ផ្លាស់ប្តូរមុខផលិតផល ឬ ផ្លាស់ប្តូរទីតាំង រោងចក្រ ក្រុមហ៊ុនត្រូវសុំការ អនុញ្ញាតពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៦ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៧ :** ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផល ព្រមទាំងត្រូវគោរពអោយ បានម៉ឺងម៉ាត់ នូវច្បាប់ ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និង ច្បាប់បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ ៨ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាស នេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៩ :** អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរ ឧស្សាហកម្ម រ៉ែ និង ថាមពលខេត្តកំពង់ចាម និង ប្រធានក្រុមហ៊ុន លៀន អ៊ី តិចថាយ ( ខេមបូឌា ) ខូអិលធីឌី ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ ១០ :** ប្រកាសនេះមានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ស៊ុយ សែម**